**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៨-០០១ សរ.ជ.ណ

ថ្ងៃសុក្រ ២រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តប្រកាសស្តីពី
# ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន

យោងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលត្រូវបានដាក់ឲ្យចូលជាធរមានដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជា សូមណែនាំបន្ថែមអំពីការអនុវត្តខ្លឹមសារនៃប្រកាសនេះ ដូចខាងក្រោម៖

## ១- ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០១៧

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមបញ្ញត្តិទាំងអស់នៃប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក រួមបញ្ចូលទាំងការគណនាសំវិធានធនលើអ៊ីមភែរមិន ក្នុងរបាយការណ៍សវនកម្មប្រចាំឆ្នាំ២០១៧។ ក្នុងករណី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបញ្ជាក់ថាមានការលំបាកក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុស្របតាមប្រកាសថ្មីនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចបន្តអនុវត្តតាមកាតព្វកិច្ចដូចការអនុវត្តកន្លងមក ចំពោះតែការបិទបញ្ជិកាគណនេយ្យសម្រាប់ឆ្នាំ២០១៧ ប៉ុណ្ណោះ។

## ២- ការរៀបចំការពិនិត្យឡើងវិញ និងការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធី

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបចំការពិនិត្យឡើងវិញជាផ្លូវការ និងគ្រប់ជ្រុងជ្រោយលើការចាត់ថ្នាក់ហ្វាស៊ីលីធីទាំងអស់របស់ខ្លួនស្របតាមវិធាននានា ដូចបានកំណត់ក្នុងប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ឲ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០១៨។ លទ្ធផលនៃការពិនិត្យឡើងវិញនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវចាប់ផ្តើមរាយការណ៍លម្អិតអំពីចំនួនហ្វាស៊ីលីធី និងទំហំទឹកប្រាក់ដក់សល់ក្នុងចំណាត់ថ្នាក់ទាំងប្រាំនៃហ្វាស៊ីលីធី ដូចមានចែងក្នុងប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក មកធនាគារជាតិនៃកម្ពុជា ឲ្យបានមុនថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។



ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

### ៣- ការវាយតម្លៃសាកល្បង អំពីសំវិធានធនលើអ៊ីមភែរមិន សម្រាប់ឆ្នាំ ២០១៨

ផ្អែកលើប្រកាសលេខ ធ៧-០១៧-៣៩៤ ប្រ.ក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបចំការវាយតម្លៃឲ្យបានពេញលេញអំពីតម្រូវការសំវិធានធនលើអ៊ីមភែរមិន ស្របតាមបញ្ញត្តិនានាចាប់ពីប្រការ ៤៩ ដល់ប្រការ ៧១ ដូចខាងក្រោម៖

- លើកទី ១៖ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគណនាសំវិធានធនលើអ៊ីមភែរមិន ដោយយកទិន្នន័យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងត្រូវរាយការណ៍លទ្ធផលនៃការគណនាសំវិធានធនលើអ៊ីមភែរមិន ទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗនៃហ្សាស៊ីលីធីមកធនាគារជាតិនៃកម្ពុជា ឲ្យបានមុនថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨។ ការវាយតម្លៃនេះនឹងជួយគ្រឹះស្ថានក្នុងការរៀបចំគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងគ្រប់គ្រាន់ដើម្បីគណនាតម្រូវការសំវិធានធនលើអ៊ីមភែរមិនដោយយោងតាមវិធានថ្មីនានា។
- លើកទី ២៖ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគណនាសំវិធានធនលើអ៊ីមភែរមិន ដោយយកទិន្នន័យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងត្រូវរាយការណ៍លទ្ធផលនៃការគណនាសំវិធានធនលើអ៊ីមភែរមិន ទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗនៃហ្សាស៊ីលីធីមកធនាគារជាតិនៃកម្ពុជា ឲ្យបានមុនថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

របាយការណ៍លទ្ធផលនេះ ត្រូវបង្ហាញឲ្យច្បាស់អំពីចំនួនសំវិធានធនលើអ៊ីមភែរមិនទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗ (Credit Risk Grading) នៃហ្សាស៊ីលីធី ដោយត្រូវឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងក្នុងការធ្វើសំវិធានធនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបចំការវាយតម្លៃសំវិធានធនខាងលើនេះ ដោយការយកចិត្តទុកដាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៤- គោលនយោបាយនិងនីតិវិធីឥណទាន

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរៀបចំ និងផ្ញើគោលនយោបាយនិងនីតិវិធីឥណទានស្របតាមប្រកាសលេខ ធ៧-០១៧-៣៩៤ ប្រ.ក មកធនាគារជាតិនៃកម្ពុជា យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ក្នុងករណី មានការធ្វើបច្ចុប្បន្នកម្មលើគោលនយោបាយនិងនីតិវិធីឥណទានដែលបានរៀបចំរួចហើយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្ញើគោលនយោបាយនិងនីតិវិធីឥណទាននោះមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពីក្រុមប្រឹក្សាភិបាលបានអនុម័ត។

ដោយផ្អែកលើរបាយការណ៍របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអំពីការធ្វើចំណាត់ថ្នាក់ និងសំវិធានធន ធនាគារជាតិនៃកម្ពុជាអាចតម្រូវឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់ព័ត៌មានបន្ថែម និងត្រូវកែប្រែគោលនយោបាយនិងនីតិវិធី ព្រមទាំងការអនុវត្តគោលនយោបាយនិងនីតិវិធីទាំងនោះ។

### ៥- ការកត់ត្រាសំវិធានធនជាក់លាក់ និងការប្រាក់បង្គរ

ក្នុងការអនុវត្តតម្រូវការសំវិធានធនតាមបទប្បញ្ញត្តិ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើសំវិធានធនជាក់លាក់ (Specific provision) ឲ្យបានគ្រប់គ្រាន់ និងកត់ត្រានៅក្នុងគណនីរបស់គ្រឹះស្ថានឲ្យបានត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់សមភាគី ហើយទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍ចំណេញ-ខាតតាមគ្រា មកធនាគារជាតិនៃកម្ពុជា។ នៅពេលណាដែលសមតុល្យគណនីរបស់អតិថិជនមានបញ្ចូលមូលធនកម្មការប្រាក់ ដែលបានកត់ត្រាបដិភាគជាមួយការប្រាក់ព្យួរទុក មូលធនកម្មការប្រាក់នេះមិនត្រូវយកមកគិតសម្រាប់គណនាសំវិធានធនទេ។

ផ្អែកលើគោលការណ៍គណនេយ្យបង្គរ (Accrual Accounting Principle) ការប្រាក់បង្គរលើហ្វាស៊ីលីធីដំណើរការ ត្រូវកត់ត្រាជាចំណូលក្នុងគណនីចំណេញ-ខាត ចំណែកការប្រាក់បង្គរលើហ្វាស៊ីលីធីទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ជាហ្វាស៊ីលីធីក្រោមស្តង់ដារ ហ្វាស៊ីលីធីសង្ស័យ ឬហ្វាស៊ីលីធីបាត់បង់ ត្រូវកត់ត្រាក្នុងខ្ទង់ទ្រព្យអកម្មនៃតារាងតុល្យការក្នុងគណនីការប្រាក់ព្យួរទុក។

### ៦- ការអនុវត្តប្លង់គណនី

ដើម្បីសម្រួលដល់ការចុះកិច្ចបញ្ជិកាគណនេយ្យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវអនុវត្តប្លង់គណនីឯកភាព (Uniform Chart of Accounts) ដូចគ្រឹះស្ថានធនាគារ។ ចំណែកឯ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តប្លង់គណនីឯកភាពដែលកំពុងប្រើប្រាស់បច្ចុប្បន្ន។

### ៧- ចំណាត់ថ្នាក់ និងសំវិធានធនតាមបទប្បញ្ញត្តិសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី

ចំណាត់ថ្នាក់និងសំវិធានធនសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លីត្រូវបានកំណត់ដូចខាងក្រោម៖

| ប្រភេទហ្វាស៊ីលីធី (រយៈពេលខ្លី) | ចំនួនថ្ងៃហួសកាលកំណត់សង | សំវិធានធនតាមបទប្បញ្ញត្តិ |
|---|---|---|
| ធម្មតា | តិចជាង ឬស្មើ ១៤ ថ្ងៃ | ១% |
| ឃ្លាំមើល | ១៥ ដល់ ៣០ ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ៣១ ដល់ ៦០ ថ្ងៃ | ២០% |
| សង្ស័យ | ៦១ ដល់ ៩០ ថ្ងៃ | ៥០% |
| បាត់បង់ | ចាប់ពី ៩១ ថ្ងៃ ឡើងទៅ | ១០០% |

### ៨- ការធ្វើសំវិធានធនសម្រាប់ខ្ទង់ក្រៅតារាងតុល្យការ

#### ក. ឥណទានវិបារូបន៍

ទំហំសំវិធានធនចំពោះឥណទានវិបារូបន៍នឹងត្រូវគណនាដោយផ្អែកលើ សមតុល្យនៃឥណទានវិបារូបន៍ដែលបានប្រើប្រាស់ ឬកម្រិតអនុម័តឥណទានវិបារូបន៍ ឬសមតុល្យដែលបានប្រើប្រាស់លើស

កម្រិតអនុម័ត អាស្រ័យលើគោលនយោបាយឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ។ ឧទាហរណ៍ ក្នុងករណីគោលនយោបាយ ឬកិច្ចសន្យារបស់គ្រឹះស្ថានចែងថា នៅពេលឥណទានវិបារូបន៍ត្រូវបានចាត់ថ្នាក់ចាប់ពីចំណាត់ថ្នាក់ឃ្លាំមើល ជាស្វ័យប្រវត្តិ អ្នកខ្ចីគ្មានសិទ្ធិ ឬមិនអាចដកយកចំណែកឥណទានដែលនៅសល់ទៅប្រើប្រាស់បាន នោះការធ្វើសំវិធានធនត្រូវផ្អែកលើសមតុល្យនៃឥណទានវិបារូបន៍ដែលបានប្រើប្រាស់។ ផ្ទុយទៅវិញ ក្នុងករណីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុគ្មានគោលនយោបាយដែលហាមឃាត់អតិថិជនដកឥណទានវិបារូបន៍យកទៅប្រើប្រាស់ដូចខាងលើទេ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើសំវិធានធនដោយផ្អែកលើកម្រិតអនុម័តឥណទានវិបារូបន៍ ឬសមតុល្យដែលបានប្រើប្រាស់លើសកម្រិតអនុម័ត។

**ខ. ខ្ទង់ផ្សេងៗទៀតនៃក្រៅតារាងតុល្យការ**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើសំវិធានធនលើកម្រិតអនុម័តនៃកិច្ចសន្យាឥណទាន ឬកិច្ចសន្យាផ្សេងទៀតដែលបានចុះកិច្ចសន្យារួចហើយ ដែលគ្រឹះស្ថានមិនអាចបដិសេធបាន ដោយសារតែកិច្ចសន្យាទាំងនេះនឹងអាចក្លាយទៅជាកាតព្វកិច្ចទូទាត់របស់គ្រឹះស្ថាន។

ចំពោះផលិតផលហិរញ្ញប្បទានពាណិជ្ជកម្ម ដូចជាលិខិតឥណទាន ឬការធានាឥណទានដែលធានាដោយប្រាក់បញ្ញើ (Margin Deposit) សំវិធានធនត្រូវគណនាដោយផ្អែកលើកម្រិតអនុម័តដកចេញប្រាក់បញ្ញើធានាដែលមានឥណប្រតិទានលើសពីឥណប្រតិទានរបស់ផលិតផលនោះ។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសាភិបាល**

ជា_ចាន់តូ

**កន្លែងទទួលៈ**
- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានត្រួតពិនិត្យ
- អគ្គនាយកដ្ឋានបច្ចេកទេស
- អគ្គបេឡា
- អគ្គាធិការដ្ឋាន
- គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ